ធនាគារពិភពលោក
កម្ពុជា
ព្រឹត្តិបត្រព័ត៌មាន



ឆ្នាំទី ៧ លេខ ៥ ខែ ឧសភា ឆ្នាំ ២០០៩

# កម្ពុជាត្រូវត្រៀមខ្លួនជាស្រេចសំរាប់ស្ថានភាពសេដ្ឋកិច្ចវិលមករកភាពប្រសើរវិញ

***ធនាគារពិភពលោកប្រចាំតំបន់អាស៊ីខាងបូព៌ា និងប៉ាស៊ីហ្វិក បានចេញផ្សាយនូវរបាយការណ៍បច្ចុប្បន្នភាពប្រចាំតំបន់ ពាក់កណ្តាលឆ្នាំរបស់ខ្លួនស្តីពីសេដ្ឋកិច្ចរបស់បណ្តាប្រទេសនានានៅក្នុងតំបន់នេះ។ កម្ពុជា គឺជាប្រទេសមួយនៃបណ្តាប្រទេសទាំងនេះ។ ព្រឹត្តិប័ត្រព័ត៌មានរបស់ធនាគារពិភពលោក បានជួបសម្ភាសន៍ជាមួយ លោក ស្ទេហ្វាន គីមប៊ែរ អ្នកសេដ្ឋកិច្ចជាន់ខ្ពស់សម្រាប់កម្ពុជា អំពីអ្វីដែលកំពុងកើតចំពោះសេដ្ឋកិច្ចកម្ពុជា។***

***សូមលោកមេត្តាជំរាបត្រួសៗ ថាតើស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្នដូចម្តេចដែរ?***

អត្រាកំណើននៅកម្ពុជា បានថយចុះយ៉ាងខ្លាំង ពីកំណើនដែលមានលេខពីរខ្ទង់ ក្នុងអំឡុងឆ្នាំ២០០៣-២០០៧ មកនៅក្រោម៦ភាគរយកាលពីឆ្នាំមុន។ យើងបានព្យាករថាកំណើនសេដ្ឋកិច្ចអាចមានលក្ខណៈអវិជ្ជមាននៅឆ្នាំនេះ។ ប្រការនេះ ត្រូវបានកើតឡើងដោយសារផលប៉ះពាល់នៃការវិវត្តពីររបស់

***តទៅទំព័រទី ២***



***សំណង់ដែលបានស្ទុះឡើងចាប់តាំងពីឆ្នាំ ២០០០ បានធ្លាក់ចុះវិញដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក រួមទាំងវិស័យកាត់ដេរ និងទេសចរណ៍ដែរ។***

# របាយការណ៍: ក្តីសង្ឃឹមចំពោះសញ្ញាងើបឡើងនៃសេដ្ឋកិច្ចប្រទេសចិន

**តូក្យូ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៩:** របាយការណ៍ពិនិត្យមើលឡើងវិញរយៈពេល៦ខែចុងក្រោយរបស់ធនាគារពិភព-លោក ស្តីអំពីសេដ្ឋកិច្ចតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បាននិយាយថា ខណៈដែលប្រទេសទាំងឡាយនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកត្រៀមខ្លួនសម្រាប់ដោះស្រាយបញ្ហាអត់ការងារធ្វើដែលរំពឹងថានឹងកើនឡើងយ៉ាងលឿនដោយសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ ប្រហែលជានឹងមានសង្ឃឹមឡើងវិញ ដោយមានសញ្ញានៃការងើបឡើងនៃសេដ្ឋកិច្ចប្រទេសចិនមុនពាក់កណ្តាលឆ្នាំ ២០០៩ ។

*របាយការណ៍បច្ចុប្បន្នភាពចុងក្រោយបំផុតស្តីពីតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក* ដែលមានចំណងជើងថា ការប្រយុទ្ធទល់នឹងកម្លាំងនៃដំណើរថយក្រោយសេដ្ឋកិច្ច និយាយថា ការងើបឡើងវិញនៅប្រទេសចិនដែលត្រូវបានជម្រុញភាគច្រើនដោយកញ្ចប់ជំនួយសេដ្ឋកិច្ចដ៏ធំសម្បើមរបស់ប្រទេសទំនងជានឹងចាប់ផ្តើមនៅឆ្នាំនេះនិងមានលក្ខណៈរឹងមាំពេញលេញក្នុងឆ្នាំ ២០១០ដែលអាចរួមចំណែកដល់ការធ្វើឱ្យមានស្ថេរភាព និងប្រហែលជាការងើបឡើងវិញនៃតំបន់នេះ។ ប៉ុន្តែ ដោយប្រទេសចិននៅតែពឹងផ្អែកខ្លាំងលើការនាំចេញទៅកាន់ទីផ្សារពិភពលោកដែលបន្តរួញចុះ *របាយការណ៍បច្ចុប្បន្នភាព*នេះព្រមានថា ការងើបឡើងប្រកបដោយចីរភាពពិតប្រាកដនៅតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិកជាចុងក្រោយ គឺអាស្រ័យលើការវិវត្តនៅក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿន។

ដោយប្រឈមទៅនឹងនាំចេញចុះខ្សោយ និងការធ្លាក់ចុះនៃតម្រូវការក្នុងស្រុកធនាគារ-ពិភពលោកកំពុងព្យាករថា កំណើនផលិតផលក្នុងស្រុកសរុប (GDP) នៅបណ្តាប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីបូព៌ា នឹងឡើងដល់ត្រឹមតែ ៥,៣ % ប៉ុណ្ណោះក្នុងឆ្នាំ ២០០៩ ថយចុះពី ៨ % ក្នុងឆ្នាំ ២០០៨ និង ១១,៤ % ក្នុងឆ្នាំ ២០០៧ (កាលពីខែមុន

***តទៅទំព័រទី ៤***

# កម្ពុជាត្រូវត្រៀមខ្លួនជាស្រេចសំរាប់ស្ថានភាពសេដ្ឋកិច្ច...

***តមកពីទំព័រទី ១***

សកលលោកមកលើកម្ពុជា: ការធ្លាក់ចុះផ្នែកតម្រូវការ (ដែលបានប៉ះពាល់លើវិស័យកាត់ដេរ និងទេសចរណ៍) និងការធ្លាក់ចុះនៃលំហូរមូលធនបរទេស (ដែលបានប៉ះពាល់លើវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា)។ ការងើបឡើងវិញនៃសេដ្ឋកិច្ចនៅកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងលើការវិវត្តនៃសេដ្ឋកិច្ចពិភពលោក និងសមត្ថភាពរបស់កម្ពុជាក្នុងការរក្សាគោលជំហររបស់ខ្លួនបានល្អសម្រាប់ការងើបឡើងវិញនេះ តាមរយៈការអនុវត្តការកែទម្រង់សមស្រប និងបង្ហាញសញ្ញាជាវិជ្ជមានដល់វិនិយោគិន។

***លោកបាននិយាយដល់វិបត្តិហិរញ្ញវត្ថុសកលលោក។ តើវាបានជះឥទ្ធិពលដល់កម្ពុជាក្នុងរយៈពេលយូរដូចម្តេចដែរ?***

ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីកំណើន យើងនៅតែបន្តមានជំនឿថា កម្ពុជាមានសក្តានុពលសម្រាប់កំណើនរយៈពេលមធ្យមពី ៦ ទៅ ៧ ភាគរយ ក្នុងមួយឆ្នាំៗ។ សក្តានុពលបែបនេះ អាចសម្រេចបាន អាស្រ័យលើទំនាក់ទំនងល្អជាបន្តជាមួយសេដ្ឋកិច្ចសកល។ ដូច្នេះ ខណៈដែលវិបត្តិសេដ្ឋកិច្ចពិភពលោក មិនមានផលប៉ះពាល់លើមាគ៌ារយៈពេលយូរ វានឹងមានផលប៉ះពាល់ដដែល ពីព្រោះការងើបឡើងវិញនៅកម្ពុជានឹងពឹងផ្អែកលើការងើបឡើងវិញរបស់បណ្តាប្រទេសដទៃទៀតនៅក្នុងពិភពលោក។ យើងក៏នៅតែពិនិត្យមើលថា តើមូលធនបរទេសនឹងមានលំហូរក្នុងកម្រិតដដែលដែរឬទេបន្ទាប់វិបត្តិនេះ។ ប្រសិនលំហូរមិនមានកម្រិតដដែលទេនោះ វានឹងតម្រូវឱ្យមានដំណើរការប្រសើរច្រើនថែមទៀតដើម្បីចលនាប្រាក់សន្សំក្នុងស្រុក។

***នៅមានប្រជាជនកម្ពុជាច្រើននាក់កំពុង រស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ តើវិបត្តិនេះមានផលប៉ះពាល់ដូចម្តេចខ្លះលើជីវភាពរស់នៅរបស់ពួកគេ?***

យើងដឹងថា ប្រាក់ចំណូលត្រូវបានប៉ះពាល់សម្រាប់ការងារមួយចំនួន (គ្មានការងារថែមម៉ោងសម្រាប់កម្មករកាត់ដេរ អ្នករត់ម៉ូតូសណ្តោង មិនសូវមានការងារធ្វើ ។ល។) ហើយកម្មករកាត់ដេរជាច្រើនបានបាត់បង់ការងារ។ យើងកំពុងធ្វើការប៉ាន់ស្មាន មួយដោយប្រើវិធីសាស្ត្រមួយដែលមានលក្ខណៈជាប្រព័ន្ធ។ ប៉ុន្តែការប៉ាន់ស្មានជំហានដំបូងដោយប្រើវិធីសាស្ត្រសាមញ្ញមួយ គឺយកតួលេខអត្រាកំណើនសេដ្ឋកិច្ចធៀប នឹងអត្រាកាត់បន្ថយភាពក្រីក្រកាលពីអតីតកាល វិធីសាស្ត្រនេះ បង្ហាញថា ភាពក្រីក្រនឹងមានការកើនឡើងយ៉ាងតិចមួយភាគរយនៅក្នុងឆ្នាំ ២០០៩ (គិតជាចំនួនមនុស្ស ពី ១០០ ០០០ ទៅ ២០០ ០០០ នាក់ នឹងធ្លាក់ក្រោមបន្ទាត់ភាពក្រីក្រ)។ យើង (ធនាគារពិភពលោក) ដៃគូអភិវឌ្ឍន៍ដទៃទៀត និងវិទ្យាស្ថាន ព្រមទាំងរដ្ឋាភិបាល កំពុងធ្វើការវិភាគបន្ថែមមួយចំនួនទៀត ដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីការវិវត្តទាំងនេះ។

***តើវិបត្តិនេះជះឥទ្ធិពលដល់ការងារនៅកម្ពុជា និងការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រដូចម្តេចដែរ?***

ដូចបានលើកឡើងខាងលើ ការបាត់បង់ការងារ និងការកាត់បន្ថយប្រាក់ចំណូល គឺជាសញ្ញានៃផលប៉ះពាល់សំខាន់ៗពីវិបត្តិនេះ។ សញ្ញាផ្សេងទៀត គឺការធ្វើចំណាកស្រុក និងការធ្លាក់ចុះនៃលំហូរប្រាក់បញ្ញើ (ប្រាក់ដែលបងប្អូនផ្ញើពីបរទេស)។ អ្នកដែលមានអាយុឈានចូលទីផ្សារការងារថ្មីចំនួន ២៥០ ០០០ នាក់ក្នុងមួយឆ្នាំៗ ក៏នឹងបង្កើតឱ្យមានបញ្ហាប្រឈមដ៏ចម្បងសម្រាប់ការងារ នៅក្នុងឆ្នាំ ២០០៩ នេះផងដែរ។ ទោះជាយ៉ាងណាក៏ដោយនៅកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតទាំងអស់ដែរ ភាពគ្មានការងារធ្វើ (និកម្មភាព) មានចំនួនតិចតួច (ដោយសារតែអ្នកដែលគ្មានការងារធ្វើ នឹងមិនអាចរស់រានបានឡើយ ប្រសិនបើគ្មានប្រាក់ចំណូលណាមួយនោះ។ ផ្ទុយទៅវិញ អ្វីដែលអាចវិវត្ត គឺការកើតឡើងស្ថានភាព "ជនក្រីក្រ" (ជាអ្នកដែលរកការងារធ្វើដើម្បីរស់ ប៉ុន្តែនៅតែរស់នៅក្រោមបន្ទាត់ក្រីក្រ ឬគ្មានឱកាសធ្វើឱ្យការចិញ្ចឹមជីវិតរបស់ខ្លួនបានប្រសើរឡើង)។ យុទ្ធសាស្ត្រដោះស្រាយផ្សេងទៀត គឺត្រូវកាត់បន្ថយការប្រើប្រាស់គ្រឿងឧបភោគបរិភោគ (ដោយជួនកាលកាត់បន្ថយមកនូវត្រឹមកញ្ចប់អាហារ ដែលមិនសូវមានជីវជាតិ ដូចមានភស្តុតាងបង្ហាញស្រាប់នៅក្នុងការអង្កេតមនុស្សសាស្ត្រនៅកម្ពុជានាពេលថ្មីៗនេះឬក៏ត្រូវលក់ទ្រព្យសម្បត្តិ។ បញ្ហាទាំងនេះគឺជាកង្វល់ដ៏ចម្បងរបស់យើង: ដែលនេះមិនមែនគ្រាន់តែមានផលប៉ះពាល់ចំពោះមុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានផលប៉ះពាល់លើការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា និងគ្រួសាររបស់ពួកគេនៅពេលអនាគតទៀតផង។

***ប្រទេសជាច្រើន បានអនុវត្តកញ្ចប់ថវិកាសម្រាប់ជំរុញកំណើន។ ចុះប្រទេសកម្ពុជាវិញយ៉ាងម៉េចដែរ?***

រដ្ឋាភិបាល បានបញ្ចូលនូវការកើនឡើងនៃឱនភាពសារពើពន្ធទៅក្នុងថវិកាដើមរបស់ខ្លួនយ៉ាងសមស្រប។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បានផ្តល់អនុសាសន៍ជាបន្តបន្ទាប់សុំឱ្យបន្ថែមកំណើនជាមធ្យមថែមទៀត។ កំណើននេះ វាមានសារៈសំខាន់ណាស់សំរាប់កំណត់គោលដៅលើចំណាយសំខាន់ៗ ដូចជាសំណើសុំឱ្យមានការបែងចែកឡើងវិញនូវចំណាយសម្រាប់វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ឬសំណាញ់សុវត្ថិភាពសង្គមដែលបានស្នើឡើង ឬមូលនិធិថ្មី សម្រាប់ការបណ្តុះបណ្តាលបុគ្គលិកដែលអស់ការងារធ្វើ។ វាក៏ជាប្រការសំខាន់ផងដែរ ដែលរដ្ឋាភិបាលមិនត្រូវ

***តទៅពីទំព័រទី ៥***

# តើវិបត្តិសលកប៉ះពាល់ដល់កម្ពុជាបែបណាៈ អត្ថបទបី

## កញ្ញា អយ ភួន



***កញ្ញា អយ ភួន អាយុ ២៦ ឆ្នាំ មកពីខេត្តកំពត ជាកម្មករកាត់ដេរៈ "ពេលនេះខ្ញុំមានការងារតិច ។ ខ្ញុំបារម្ភ ។ ប្រសិនបើខ្ញុំបាត់បង់ការងារនេះ ខ្ញុំនឹងរកការងារផ្សេងទៀត ប៉ុន្តែ ប្រសិនបើរកការងារមិនបានខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ ។ ពីមុនខ្ញុំរកបានជាង ៧០ ដុល្លា ក្នុងមួយខែៗ ប៉ុន្តែពេលនេះខ្ញុំរកបានតែ ៣០ ដុល្លាទេ។ ខ្ញុំធ្លាប់ផ្ញើលុយទៅផ្ទះ ១០ ឬ ១៥ ដុល្លារៀងរាល់ខែ ប៉ុន្តែពេលនេះ ខ្ញុំមិនបានផ្ញើប្រាក់ទៅផ្ទះទេ"។***

### សាវតា

កញ្ញា ភួន មកពីស្រុកកំពង់ត្រាច ខេត្តកំពត ។នាងបានធ្វើការនៅរោងចក្រកាត់ដេរនេះជាងមួយឆ្នាំហើយ ។ពីមុននាងធ្វើជាអ្នកបំរើនៅផ្ទះរបស់គ្រួសារមួយនៅភ្នំពេញ ។

### តើសហការីភាគច្រើនរបស់នាងនៅតែធ្វើការនៅទីនោះទេ?

អត់ទេ ពួកគេជាច្រើននាក់បានឈប់ហើយ ហើយទៅរកការងារថ្មីដែលមានកំរៃច្រើននៅរោងចក្រផ្សេងទៀត ពីព្រោះតែរោងចក្របាត់បងការបញ្ជាទិញ ហើយកាត់ពេលម៉ោងធ្វើការ និងម៉ោងធ្វើការបន្ថែម។ ដូចនេះហើយចំណូលរបស់មិត្តភ័ក្តិនាងទាបដែលលំបាកក្នុងការចំណាយសំរាប់ឈ្នួលផ្ទះ និងចំណាយលើការរស់នៅផ្សេងៗ។

### អ្វីជាការព្រួយបារម្ភសំរាប់អនាគត?

នាងមានការបារម្ភដែរចំពោះអនាគត។ ប្រសិនបើនាងបាត់បង់ការងារនៅរោងចក្រកាត់ដេរ នាងនឹងទៅរកការងារនៅកន្លែងផ្សេងទៀត។ ប្រសិនបើគ្មានការងារទេ នាងនឹងត្រឡប់ទៅផ្ទះវិញ ទៅធ្វើស្រែ។

### តើចំណូលរបស់នាងប៉ុន្មានក្នុងមួយខែ?

នាងធ្លាប់បានទទួលប្រាក់ខែ ៧០ ដុល្លា ក្នុងមួយខែៗ ប៉ុន្តែខែនេះ នាងបានទទួលតែ ៣០ ឬ ៤០ ដុល្លា ដោយសារតែរោងចក្រគ្មានបញ្ជាទិញ ។ នេះមានន័យថា កម្មករត្រូវបានឱ្យឈប់ធ្វើការប្រមាណ ២ សប្តាហ៍ក្នុង មួយខែ ដូចនេះទទួលបានប្រាក់ខែតែពាក់កណ្តាល ។

### តើប្រាក់ខែនេះសំរាប់ផ្គត់ផ្គង់អ្នកណា?

កាលពីប៉ុន្មានខែមុន នាងបានផ្ញើទៅផ្ទះប្រមាណ ១០ ទៅ ១៥ ដុល្លា ក្នុងមួយខែៗ។ ប៉ុន្មាននៅខែចុងក្រោយនេះនាងគ្មានលុយផ្ញើទៅទេ ។ នាងផ្គត់ផ្គងឪពុកម្តាយនាង និងប្អូនប្រុស និងប្អូនស្រីនាង ៤ នាក់ ។ប្អូនប្រុសរបស់នាងម្នាក់ធ្វើកម្មករនេសាទនៅខេត្តព្រះសីហនុ ប៉ុន្តែវាមិនមានលុយដើម្បីផ្ញើមកជួយគ្រួសារទេ។

### នាងនឹងធ្វើការងារអ្វីនៅខែក្រោយ?

ខែក្រោយ (ខែមេសា) រោងចក្រទទួលបានបញ្ជាទិញបន្ថែម ដូចនេះនាងនឹងមានការងារធ្វើទៀត ហើយសង្ឃឹមថានឹងទទួលបានប្រាក់ខែ ៥០ ដុល្លាក្នុងមួយខែ ។

## កញ្ញា ហង សុផានី



***ហង សុផានី អាយុ ២៧ ឆ្នាំ ម្ចាស់ហាងបំរើសេវាទេសចរណ៍ៈ "ខ្ញុំធ្លាប់មានភ្ញៀវច្រើនមកពីរោងចក្រកាត់ដេរ ប៉ុន្តែពេលនេះមានរោងចក្រច្រើនបិទ មានន័យថា សេវាកម្មខាងវីសាបានធ្លាក់ចុះ ៧០ % ហើយ ៣០ % គឺជាភ្ញៀវរបស់ខ្ញុំរយៈពេលវែង ។ ខ្ញុំមានការព្រួយបារម្ភសំរាប់អនាគត ដូចនេះ ខ្ញុំបានបង្កើតជាសេវាអ៊ីនធ័រណែត និងបង្កើតមុខរបបផ្សេងៗទៀត"។***

### សាវតា

សូផានី បានបើកហាងរបស់នាងកាលពីខែមិថុនាឆ្នាំ ២០០៨ នៅភ្នំពេញ។ពីមុនមកនាងបំរើការងារនៅភ្នាក់ងារទេសចរណ៍ជាង ៣ឆ្នាំ ។ មុខរបបរបស់នាងកាក់កបល្អប្រសើរមុនដំបូង។

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកវាមានការលំបាក និងខាតបង់ប្រាក់របស់នាងមួយចំនួន។ ហាងរបស់នាង បំរើសេវាកម្មលើផ្នែកពីរសំខាន់ៈ សេវាកម្មវីសាសំរាប់បុគ្គលិកគ្រប់គ្រងជនជាតិចិនដែលបំរើការ នៅរោងចក្រកាត់ដេរ និងលក់សំបុត្រយន្តហោះ និងសំបុត្ររថយន្តក្រុង។

ផលប៉ះពាល់ដែលអាក្រក់ជាងគេនោះគឺការបិទរោងចក្រកាត់ដេរច្រើន។ វាបានប៉ះពាល់ដល់របររបស់នាង ដោយបុគ្គកិច្ចគ្រប់គ្រងជនជាតិចិនជាងពាក់កណ្តាលដែលធ្វើវីសាតាមរយៈសេវាកម្មរបស់នាងបានត្រឡប់ទៅស្រុកវិញ។

នាងបានរក្សាភ្ញៀវប្រមាណ ៣០ ភាគរយដែលនៅតែប្រើប្រាស់សេវារបស់នាងសំរាប់វីសា

តទៅទំព័រទី ៦

# របាយការណ៍៖ ក្ដីសង្ឃឹមចំពោះសញ្ញាងើបឡើងនៃសេដ្ឋកិច្ចប្រទេសចិន

***តមកពីទំព័រទី ១***

នៅក្នុង*របាយការណ៍បច្ចុប្បន្នភាពប្រចាំត្រីមាសប្រទេសចិន* ធនាគារពិភពលោកបានបន្ទាបការព្យាករណ៍របស់ខ្លួនសម្រាប់កំណើននៃប្រទេសចិនមកត្រឹម ៦,៥% ក្នុងឆ្នាំនេះ ពី ១៣ % ក្នុងឆ្នាំ ២០០៧) ។

បណ្ដាប្រទេសមានប្រាក់ចំណូលទាប នៃតំបន់នេះ ត្រូវបានគេរំពឹងថានឹងស្ថិតនៅក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេដោយការធ្លាក់ចុះនេះ និងកំរិតលទ្ធភាពសម្រាប់អន្តរាគមន៍របស់រដ្ឋាភិបាលដើម្បីជួយប្រជាជនទាំងឡាយដែលជួបការលំបាក។ កម្ពុជាទំនងជានឹងជួបប្រទះការធ្លាក់ចុះខ្លាំងបំផុតនៅក្នុងកំណើនដោយសារការធ្លាក់ចុះនៅក្នុងវិស័យកាត់ដេរ និង ទេសចរណ៍ ខណៈដែលប្រទេសឡាវ ម៉ុងហ្គោលី ប៉ាពួញូវហ្គីណេ និងទីម័រឡេស្តេ នឹងរងផលប៉ះពាល់ខ្លាំងជាពិសេស ដោយសារតម្លៃទំនិញទាប។

នៅពេលចេញដំណើរទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី ១៣ នៅប៉ាតាយ៉ា ប្រទេសថៃ លោក ជីម អាដាម អនុប្រធានធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានសរសើររដ្ឋាភិបាលនៃតំបន់នេះ ចំពោះការឆ្លើយតបយ៉ាងលឿនទៅកាន់វិបត្តិហិរញ្ញវត្ថុ ជាមួយនឹងកិច្ចប្រឹងប្រែខាងគោលនយោបាយពហុមុខព្រួញ ចាប់តាំងពីកញ្ចប់ជំនួយសារពើពន្ធ រហូតដល់អន្តរាគមន៍គោលនយោបាយរូបិយវត្ថុ រហូតដល់កម្មវិធីសំណាញ់សុវត្ថិភាពសង្គម។

លោក អាដាមស៍ បានមានប្រសាសន៍ថា *"វិធានការនានាដែលអាជ្ញាធរបានប្រកាន់យកដើម្បីទប់ទល់នឹងវិបត្តិ នៅទូទាំងតំបន់កំពុងជួយសម្រាលផលប៉ះពាល់លើប្រជាជនងាយរងគ្រោះបំផុត"* ។ លោកបន្តថា *"ជាមួយភាពគ្មានការងារធ្វើទំនងជានឹងកើនឡើង ជាពិសេស ខណៈដែលការងារនៅក្នុងវិស័យកម្មន្តសាល និងសំណង់បាត់បង់កិច្ចប្រឹងប្រែងការពារសង្គមកិច្ចនឹងចាំបាច់ត្រូវពង្រីក ដើម្បីបំពេញសេចក្ដីត្រូវការជាក់ស្ដែងរបស់មនុស្ស ។"*

របាយការណ៍បច្ចុប្បន្នភាពនេះក៏បានលើកឡើងថា ការចុះខ្សោយនៃកំណើននេះ ត្រូវបានគេរំពឹងថានឹងប៉ះពាល់ដល់ល្បឿននៃការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ គឺថាប្រជាជនជាង ១០ លាននាក់ ថែមទៀតទំនងជាស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រក្នុងឆ្នាំនេះប្រៀបធៀបទៅនឹងការប៉ាន់ស្មានកាលពីមួយឆ្នាំមុន។ ប្រទេសកម្ពុជា ម៉ាឡេស៊ី ថៃឡង់ដ៏ និងទីម័រឡេស្តេ ត្រូវបានព្យាករថា នឹងជួបប្រទះការកើនឡើងចំនួននៃភាពក្រីក្រក្នុងឆ្នាំនេះ។

របាយការណ៍នេះនិយាយថា តំបន់នេះកំពុងបង្កើនកិច្ចប្រឹងប្រែង ដើម្បីជួយឧបត្ថម្ភប្រជាជនក្រីក្រ និងងាយរងគ្រោះ ជាពិសេសក្នុងបណ្ដារប្រទេសមានប្រាក់ចំណូលមធ្យម។ នៅចុងឆ្នាំ២០០៨ ប្រទេសចិនបានផ្ដល់ការផ្ទេរប្រាក់មួយដងជូនដល់ប្រជាជន ជាងចំនួន ៧៤ លាននាក់ រួមមានគ្រួសាររាប់លាននៅជនបទ និងបានដាក់ឱ្យអនុវត្តការកាត់បន្ថយពន្ធក៏ដូចជាកញ្ចប់កំណែទម្រង់វិស័យសុខាភិបាលដ៏ធំមួយដើម្បីបង្កើនលទ្ធភាពទទួលបានការថែទាំសុខភាពជូនប្រជាជនក្រីក្រ។ ប្រទេសឥណ្ឌូណេស៊ីបានជួយឧបត្ថម្ភគ្រួសារក្រីក្រចំនួន ១៩ លានគ្រួសារ ដោយអនុវត្តឡើងវិញនូវកម្មវិធីជំនួយសាច់ប្រាក់គោលដៅ ហើយប្រទេសហ្វីលីពីន កំពុងបង្កើនចំនួនប្រជាជនក្រីក្រ ដែលត្រូវបានរាប់បញ្ចូលក្នុងកម្មវិធីផ្ទេរសាច់ ប្រាក់មានលក្ខខណ្ឌដែលទើបត្រូវបានដាក់ឱ្យអនុវត្តនៅពេលថ្មីៗនេះ។

លោក វិក្រាម ណេរូ ប្រធានសេដ្ឋកិច្ចនៃធនាគារពិភពលោកសម្រាប់តំបន់ បានមានប្រសាសន៍ថា *"គេគ្មានការសង្ស័យឡើយថា តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កំពុងជួបប្រទះសម័យកាលដ៏លំបាកខ្លាំង"*។ លោកបានបន្តថា *"ប្រទេសទាំងឡាយដែលអាចដោះស្រាយ បញ្ហាប្រឈមរយៈពេលខ្លីទន្ទឹមគ្នានឹងការ ផ្ដោតការយកចិត្តទុកដាក់លើអាទិភាពរយៈពេលវែង ទំនងជានឹងមានស្ថានភាពប្រសើរជាងគេ ក្រោយពេលវិបត្តិ និងដើម្បីចាប់ផ្ដើមឡើវិញនូវកំណើន។"*

លោក ណេរូ បានបន្តថា ខណៈដែលសេដ្ឋកិច្ចពិភពលោកងើបឡើងវិញយ៉ាងយឺត បណ្ដាប្រទេសនៅតំបន់នេះ អាចសម្រេចបានអត្រាកំណើនខ្ពស់ ប្រសិនបើពួកគេលើកស្ទួយភាពប្រកួតប្រជែងរបស់ខ្លួនចូលទីផ្សារថ្មី និងគាំទ្រក្រុមហ៊ុនឱ្យច្នៃប្រឌិតថ្មី ជាជាងការចម្លងតាមគេ។

## ប្រទេសកម្ពុជា

ជាមួយនឹងផលប៉ះពាល់នៃការធ្លាក់ចុះចលនាសេដ្ឋកិច្ចពិភពលោក សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងធ្លាក់ចុះដល់កំរិត - ១ %) ក្នុងឆ្នាំ២០០៩ ក្រោយពីបានថយចុះមកត្រឹម ៥,៥ % នៅក្នុងឆ្នាំ ២០០៨ បន្ទាប់ពីអំឡុងពេលមួយនៃកំណើនខ្ពស់ជាប់ៗគ្នា។ តែទោះជាយ៉ាងណាក៏ដោយ ការព្យាករណ៍សម្រាប់ឆ្នាំ ២០១០ មានលក្ខណៈមិនប្រាកដប្រជាខ្លាំង ប៉ុន្តែអាចស្ថិតក្នុងរង្វង់ ០-៤ % ប្រសិនបើតម្រូវការខាងក្រៅមានលក្ខណៈគាំទ្រ។

លោក ស្ដេហ្វាន ហ្គីមប៊ែរ អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំប្រទេសនៃធនាគារពិភពលោក មានប្រសាសន៍ថា*ការសម្រេចបានដ៏គួឱ្យគត់សំគាល់នាទស្សវត្សកន្លងទៅ និងការងើបឡើងវិញនៃសេដ្ឋកិច្ចកំពុងត្រូវបានគេសាកល្បងសំរាប់ការដើរថយក្រោយវិញនៃសេដ្ឋកិច្ចពិភពលោក"* ។ លោកបានបន្តថា *"ពន្លឺនៃក្ដីសង្ឃឹមសម្រាប់កម្ពុជាគឺស្ថិតនៅលើសក្តានុពលកំណើនដ៏ខ្លាំងរបស់ខ្លួនក្នុងរយៈពេលមធ្យម"* ។

លោកបានបន្តថា កំណើននឹងអាចប្រសើរឡើងវិញនៅឆ្នាំ ២០១០ បើទោះបីជាភាពមិនប្រាកដប្រជានៅមានទំហំធំក្ដី។

ធនាគារពិភពលោកកំពុងជួយគាំទ្របណ្ដាប្រទេសនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក នៅពេលដែលប្រទេសទាំងនេះជួបប្រទះនឹងផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ តាមរយៈការបង្កើនហិរញ្ញប្បទាន និងការបង្កើនឱវាទគោលនយោបាយអំពីវិធីការពារប្រជាជនក្រីក្រនិងអ្នកដែលងាយរងគ្រោះ។

# កម្ពុជាត្រូវត្រៀមខ្លួនជាស្រេចសំរាប់ស្ថានភាពសេដ្ឋកិច្ច...

***តមកពីទំព័រទី ២***

បណ្តោយឱ្យផលដែលសម្រេចបានដោយលំបាកបាត់បង់ទៅវិញលើការប្រមូលចំណូល និងដែលដៃគូត្រូវគោរពពាក្យសន្យារបស់ខ្លួនដែលបានធ្វើឡើងនៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយគួរកត់សម្គាល់ថា កម្ពុជា ក៏ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនដែរ គឺមានកញ្ចប់ថវិកាសំរាប់ជំរុញកំណើនតូច ហើយ បើធ្វើឱ្យវាធំ វានឹងអាចធ្វើឱ្យប៉ះពាល់ខ្លាំងដល់ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើននាពេលអនាគត។

***តើសេដ្ឋកិច្ចកម្ពុជា នឹងប្រើពេលយូរប៉ុន្មានដើម្បីងើបឡើងវិញពីវិបត្តិនេះ?***

ការងើបឡើងវិញ ពឹងផ្អែកយ៉ាងខ្លាំងលើតម្រូវការ និងមូលធនខាងក្រៅ។ ការព្យាករនានាដែលបានធ្វើឡើងនាបច្ចុប្បន្ននេះ មិនរំពឹងថានឹងមានការងើបឡើងវិញជាសកលមុនដើមឆ្នាំ២០១០ទេ។ ដូច្នេះ សកម្មភាពសេដ្ឋកិច្ចកម្ពុជាទំនងដូចជាមានការយឺតយ៉ាវពេញមួយឆ្នាំ។

***តើធនាគារពិភពលោកមានតួនាទីអ្វីខ្លះ ដើម្បីជួយកម្ពុជាក្នុងការទប់ទល់នឹងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចនេះ?***

យើងកំពុងធ្វើការរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត លើមូលដ្ឋានបីយ៉ាងៈ ទីមួយ ដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីការវិវត្តផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗនេះ ភាពក្រីក្រ និងផលវិបាកសង្គមនៃការវិវត្តទាំងនេះ។ ផ្នែកនេះ នឹងតម្រូវឱ្យធ្វើការងារបន្ថែមលើការពិនិត្យតាមដាន ការប្រមូលទិន្នន័យ និងការវិភាគ។ ទីពីរ ការបង្កើនល្បឿននៃការអនុវត្តកម្មវិធីដែលមានស្រាប់ គឺជាមធ្យោបាយដ៏លឿនបំផុត ដើម្បីឆ្លើយតបទៅនឹងវិបត្តិនេះ។ យោងតាមការណែនាំ របស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានលើកឡើងនៅក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជា ដែលបានប្រព្រឹត្តិទៅកាលពីខែកុម្ភៈ ឆ្នាំ២០០៩ យើងបានពិនិត្យឡើងវិញលើចំណុចដែលត្រូវបង្កើនល្បឿនការអនុវត្ត ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច ជាពិសេសផលប៉ះពាល់លើជនដែលងាយរងគ្រោះបំផុត។ យើងក៏នឹងពិភាក្សាអំពីប្រតិបត្តិការគោល-នយោបាយអភិវឌ្ឍន៍ដែលមានទឹកប្រាក់ចំនួន ១៣ លានដុល្លាអាមេរិក ដោយផ្តោតលើកសិកម្មខ្នាតតូច និងសំណាញ់សុវត្ថិភាពសង្គម។ ទីបី យើងបានចូលរួមពិភាក្សាជាមួយរដ្ឋាភិបាល ដើម្បីផ្តល់យោបល់អំពីការឆ្លើយតប ឱ្យបានគ្រប់គ្រាន់ចំពោះវិបត្តិនេះ ដែលតាមទស្សនៈរបស់យើង រាប់បញ្ចូលការឆ្លើយតបផ្នែកគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ផ្នែកសារពើពន្ធ (រួមបញ្ចូលទាំងការអនុវត្តសំណាញ់សុវត្ថិភាពសង្គម) និងផ្នែកកំណែទម្រង់បរិស្ថានអាជីវកម្ម។ នៅពេលណាក៏ដោយឱ្យតែអាចធ្វើបាន ឧទាហរណ៍ តាមរយៈគម្រោងពាណិជ្ជកម្មរបស់យើង និងជាមួយសហសេវិករបស់យើងមកពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ យើងត្រៀមខ្លួនដើម្បីគាំទ្រចំពោះការអនុវត្តសកម្មភាពឆ្លើយតបរបស់រដ្ឋាភិបាលចំពោះវិបត្តិនេះ។

បញ្ហាទាំងអស់នេះ គឺជាប្រធានបទដ៏សំខាន់សម្រាប់ការពិភាក្សារបស់គណៈកម្មាធិការសម្របសម្រួល រដ្ឋាភិបាល-ម្ចាស់ជំនួយ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩។

***ជារឿយៗ ការព្យាករណ៍របស់ធនាគារពិភពលោក និងស្ថាប័នអន្តរជាតិដទៃទៀតមានភាពខុសគ្នា។ តើលោកមានប្រតិកម្មដូចម្តេចដែរ?***

ភាពខុសគ្នាជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ឆ្លុះបញ្ចាំងពីភាពមិនប្រាកដនិយមចំនួនបី។ ទីមួយ សេណារីយ៉ូសម្រាប់សេដ្ឋកិច្ចសកល ដែលមានផលប៉ះពាល់លើកម្ពុជា តាមរយៈវិស័យកាត់ដេរ និងទេសចរណ៍ និងតាមរយៈវិនិយោគបរទេសនៅតែមានភាពខុសគ្នានៅឡើយដោយបន្ដឆ្លុះបញ្ចាំងពីភាពមិនប្រាកដនិយមជាសកល។ ទីពីរ ដោយសារភាពមិនប្រាកដនិយមនេះ និងកម្រង "សូចនាករនាំមុខ" មានកម្រិត អ្នកវិភាគអាចធ្វើការសន្និដ្ឋានផ្សេងៗគ្នា។ ឧទាហរណ៍ នៅក្នុងផ្នែកកាត់ដេរ កម្លាំងពលកម្មចំនួន ១៤ ភាគរយ បានជួបប្រទះបញ្ហាអត់ការងារធ្វើរួចទៅហើយ។ ការនាំចេញនៅក្នុងខែមករា-កុម្ភៈ បើនិយាយឱ្យត្រឹមត្រូវតាមរដូវស្មើនឹង១៤ភាគរយក្រោមមធ្យមភាគនៅក្នុងឆ្នាំ២០០៨។ ក្រុមហ៊ុននានាបានរាយការណ៍ថា ការបញ្ជាទិញមានចំនួនពី២០-៤០ ភាគរយក្រោមកម្រិតធម្មតា។ ដូច្នេះ ការព្យាករណ៍របស់យើងបង្ហាញនូវការថយចុះចំនួន ១០ ភាគរយសម្រាប់មួយឆ្នាំទាំងមូល។ មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី សន្និដ្ឋានថា មានការថយចុះតែ៥ ភាគរយ ប៉ុណ្ណោះ។ ទីបី ការងើបឡើងនៃផ្នែកក្រៅប្រព័ន្ធ នឹងជួបប្រទះការលំបាក។ ដូចរដ្ឋាភិបាលដែរ យើងមានជំនឿថា ការងើបឡើងវិញនឹងមានភាពរឹងមាំ។ ទោះបីជាយ៉ាងណាក៏ដោយ យើងបានកត់សម្គាល់ថា ការងារមួយចំនួននៅក្នុងវិស័យក្រៅប្រព័ន្ធ ដូចជា កម្មករសំណង់ដែលគ្មានជំនាញ អ្នករត់ម៉ូតូសណ្តោង ហាងលក់បន្លែតូចតាចបច្ចុប្បន្ន រកចំណូលបានតិចជាងកាលពីឆ្នាំមុន (ទិន្នន័យរបស់វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា) : នេះទំនងជានឹងបណ្តាលឱ្យមានការយឺតយ៉ាវ (ទោះបីជាមិនមែនជាការថយចុះក៏ដោយ) លើកំណើននៃផ្នែកក្រៅប្រព័ន្ធ។

***ព័ត៌មានបន្ថែម សូមទាក់ទង***
***លោក ស្តេហ្វាន គីមប៊ែរ***
***អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំកម្ពុជា***
***Email: sguimbert@worldbank.org***

# តើវិបត្តិសេដ្ឋកិច្ចប៉ះពាល់ដល់កម្ពុជាបែបណា៖ អត្ថបទបី

***តមកពីទំព័រទី ៣***

និងទិញវីសាថ្មី ។

***អ្វីដែលទប់ទល់មុខរបររបស់នាងបាន?***

ដោយសារតែវិបត្តិនេះ នាងបានបង្កើតសេវាផ្សេងៗទៀត ។ នាងបានដាក់បន្ថែមសេវាអ៊ីនធឺណែតក្នុងហាងរបស់នាង ។ ពេលនេះមានស្ថានទូតលោកខាងលិច បានអនុម័តឱ្យនាងបំរើសេវាវីសាជូនប្រជាជនខ្មែរ ។

មុខរបររបស់នាងពេលនេះអាស្រ័យលើការលក់សេវាវីសាទេសចរណ៍ និងសំបុត្រយន្តហោះសំរាប់ជនបរទេស ដែលមាន បំណងចង់មកលេងល្បែងនៅកាស៊ីណូនៅភ្នំពេញ ។ នាងក៏មានលក់សំបុត្ររថយន្តក្រុងផងដែរ ។ សេវាទាំងពីរនេះ បានជួយឱ្យហាងរបស់នាងអាចទប់ទល់បាននាពេលនេះ ។ ចំណូលរបស់នាងបានធ្លាក់ចុះ ៥០ ភាគរយ ចាប់តាំងពីបំណាច់ឆ្នាំ ២០០៨ ។

ផែនការទៅអនាគត នាងមានការព្រួយបារម្ភអំពីអនាគត ហើយនាងមិនទាន់មានគំនិតថានឹងត្រូវធ្វើអ្វីទៀតទេ ។ ប៉ុន្តែនាងប្រហែលជារករបរអ្វី ដែលទាក់ទិននឹងទេសចរណ៍ ។ នាងប្រហែលជានឹងត្រូវបិទហាង ហើយចាប់ផ្តើមធ្វើការនៅផ្ទះព្រោះអាចសន្សំបានមួយខែ ៤០០ ដុល្លាពីតំលៃជួលហាងនោះ ដោយសារតែភាគច្រើននៃភ្ញៀវរបស់នាងមិនបានមកហាងនាងទេ ។ នាងនឹងមានសុទិដ្ឋិនិយម ល្គឹកណាហាងរបស់នាងអាចដំណើរការបន្តទៀតបាន ។

## រស់ វីយ៉ា

***រស់ វីយ៉ា ៖ "ពេលនេះមិនសូវមានការងារទេ ។ មិត្តភក្តិខ្ញុំជាច្រើននាក់គ្មានការងារធ្វើទេ ដោយសារតែរោងចក្រមួយចំនួនបានបិទទ្វា ។ ដូចនេះពួកគេរកការងារធ្វើជាកម្មករសំណង់ ។ ការងារខ្ញុំមុនបានប្រាក់ខែ ១០០ ដុល្លា ក្នុងមួយខែ ។ ខ្ញុំផ្ញើលុយទៅផ្ទះខ្លះ ហើយលុយនៅសល់ខ្ញុំចាយនៅទីនេះ" ។***




***សាវតា***

វីយ៉ា អាយុ ២០ឆ្នាំ មកពីខេត្តព្រៃវែង ។ មិត្តភក្តិគាត់ជាច្រើនបាត់បងការងារជាកម្មកររោងចក្រនាពេលថ្មីៗនេះ ហើយបានទៅធ្វើជាកម្មករសំណង់ ។ វីយ៉ាបានបំរើការងារជាសន្តិសុខចំនួន ៣ ឆ្នាំ ទទួលបានប្រាក់ខែ ១០០ ដុល្លា ក្នុងមួយខែ ។ វីយ៉ាផ្ញើប្រាក់ខែពាក់កណ្តាលទៅផ្ទះសំរាប់ជួយគ្រួសារ ។

***ក្តីបារម្ភរបស់វីយ៉ាសំរាប់អនាគត?***

វីយ៉ាបារម្ភខ្លះៗដែរអំពីអនាគតដោយសារតែវិបត្តិសេដ្ឋកិច្ចដែលមិនមានភាពនឹងន់ ។ ពេលដែលវិបត្តិនេះប៉ះពាល់ វានឹងធ្វើឱ្យប៉ះពាល់ដល់វីយ៉ាដែរ ។ ប្រសិនបើវាប៉ះពាល់ដល់វីយ៉ា វីយ៉ានឹងត្រឡប់ទៅផ្ទះវិញ ។

***តើអ្វីជាផែនការរបស់វីយ៉ាទៅអនាគត?***

វីយ៉ាមិនមានលុយសន្សំទេ ដូចនេះវីយ៉ាមិនទាន់មានផែនការទេ ។ ខែនេះ វីយ៉ាមិនសល់លុយទេ ដោយសារតែខែមុន វីយ៉ាបានឈប់ធ្វើការងារជាសន្តិសុខ ដូចនេះវីយ៉ាក៏មិនបានផ្ញើលុយទៅផ្ទះដែរ ។

បើទោះបីជាមានការងារក្រៅម៉ោងច្រើនពេលដែលវីយ៉ាធ្វើជាសន្តិសុខក៏ដោយ ក៏វីយ៉ាសំរេចចិត្តឈប់ធ្វើការងារនេះ ដោយសារតែថៅកែបើកប្រាក់ខែយឺតជារៀងរាល់ខែ ។ វីយ៉ាត្រូវការលុយបើកឱ្យទាន់ខែ ដើម្បីបំពេញតំរូវការចំណាយ និងផ្ញើទៅផ្ទះដើម្បីផ្គត់ផ្គង់ឪពុកម្តាយ ។

ឧស្សាហកម្មសំណង់បានថយចុះក្នុងរយៈពេល ៦ ខែចុងក្រោយនេះ ។ វីយ៉ាមានការលំបាកក្នុងការរកការងារធ្វើ ។ ពេលនេះវីយ៉ារកបានហើយ ហើយមានការងារជាច្រើននៅការដ្ឋានសំណង់នោះ ។ ដោយសារតែនេះជាខែដំបូងរបស់ប្អូន វីយ៉ាមិនទាន់ដឹងថានឹងទទួលបានប្រាក់ខែប៉ុន្មានទេ ។ វីយ៉ាក៏មិនដឹងថានឹងផ្ញើលុយទៅផ្ទះប៉ុន្មានដែរ ។

***ការផ្គត់ផ្គង់ជីវភាពគ្រួសាររបស់វីយ៉ា?***

វីយ៉ាមិនមែនផ្គត់ផ្គង់ឪពុកម្តាយតែម្នាក់ឯងនោះទេ ។ ឪពុកម្តាយវីយ៉ាមានដីស្រែតូចមួយ និងធ្វើស្រែ ។ បងប្អូនប្រុសពីរនាក់ ធ្វើជាសន្តិសុខក៏បានជួយផ្គត់ផ្គង់ឪពុកម្តាយ ។ ដោយមូលហេតុនេះហើយបានជាកាលពីខែមីនា វីយ៉ាមិនបានផ្ញើលុយទៅផ្ទះក៏មិនជាបញ្ហាដែរ ។ វីយ៉ាបានជំរាបថា ក្រុមហ៊ុនដែលខ្លួនកំពុងធ្វើការប្រហែលជាបញ្ជូនគាត់ឱ្យទៅធ្វើការនៅខេត្តព្រោះក្រុមហ៊ុននេះធំ ហើយមានការងារច្រើននៅក្នុងប្រទេស ។

**ថ្មី!**




ធនាគារពិភពលោកប្រចាំកម្ពុជាទើបបានបោះពុម្ពផ្សាយនូវឯកសារថ្មី មានចំណងជើងថា "កំណើនលឿន ក្នុងបរិយាកាសប្រឈម" ។ ឯកសារនេះអាចរកបាននៅការិយាល័យធនាគារពិភពលោក ។

ធនាគារពិភពលោក ការិយាល័យនៅកម្ពុជា ផ្ទះលេខ ១១៣ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ ៨៥៥ ២៣ ២១៧ ៣០១ និង ទូរសារលេខ ៨៥៥ ២៣ ២១០ ៥០៤ វេបសាយជាភាសាខ្មែរ www.worldbank.org.kh និងជាភាសាអង់គ្លេស www.worldbank.org/kh